ក្រសួងការពារជាតិ

## សារជូនពរ

**សូមគោរពជូន**

**សម្តេចអគ្គមហាពញាចក្រី សាយ ឈុំ ប្រធានព្រឹទ្ធសភា**
**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ**

**សម្តេចអគ្គមហាពញាចក្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏មង្គលសួស្តីប្រសើរថ្លៃថ្លា ប្រកបដោយសេចក្តីសោមនស្សរីករាយ នៃការទទួលអំណរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខមហាប្រសើរ ជូនចំពោះ **សម្តេចអគ្គមហាពញាចក្រី** ទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួន បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំព្រឹទ្ធសភាជាតិ ដែលជាស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជាសម្រេចបាននូវលទ្ធផលគ្រប់គ្រាន់ថ្មីៗថែមទៀត។

នាឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពយ៉ាងជ្រាលជ្រៅបំផុតមិនអាចបំភ្លេចបានចំពោះសកម្មភាពប្រកបដោយគុណវិភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាពញាចក្រី** តែងតែបានយកអស់កម្លាំងកាយចិត្ត និងរាល់បទពិសោធន៍ក្នុងការដឹកនាំព្រឹទ្ធសភា ឱ្យក្លាយជាស្ថាប័ននីតិប្បញ្ញត្តិប្រកបដោយសក្តានុពលដើម្បីនាំនាវាកម្ពុជាឆ្ពោះទៅរកនីតិរដ្ឋមួយដែលជាមូលដ្ឋានគ្រឹះ ជំរុញការអភិវឌ្ឍប្រទេសជាតិមានការរីកចម្រើនលើគ្រប់វិស័យស្របតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋគ្រប់រូប។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ក្នុងនាមខ្ញុំនិងភរិយា សូមលើកហត្ថប្រណម្យចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោកសូមព្រះអង្គតាមជួយបីបាច់ថែរក្សាប្រោះព្រំសព្ទសាធុការពរជ័យ សិរីមង្គលជូនចំពោះ **សម្តេចអគ្គមហាពញាចក្រី** និង**លោកជំទាវ** ព្រមទាំងបុត្រាបុត្រី ចៅប្រុសចៅស្រីជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចអគ្គមហាពញាចក្រី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃអង្គារ ១០កើត ខែ ចេត្រ ឆ្នាំឆ្លូវ ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០២១
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២៧៨: generalsec@mod.gov.kh